académie
Reims
éducation
nationale
enseignement
supérieur
recherche

Khmer

**P.R.I.P.I**
កម្មវិធី
ភូមិភាគនៃការចូលរួម
របស់ប្រជាជនអន្តោប្រវេសន៍

**C.A.S.N.A.V**
មជ្ឈមណ្ឌលនៃបណ្ឌិតសភា
សម្រាប់ការសិក្សា
នៃអស់អ្នកដែលទើបមកដល់
និងកូនអ្នកធ្វើដំណើរ

# ការសិក្សានៅប្រទេសបារាំង

*ឯកសារសំរាប់ទទួល*
*គ្រួសារ*
*និង*
*សិស្សានុសិស្សថ្មី*
*ដែលទើបមកដល់ប្រទេសបារាំង*

## ឯកសារនេះឆ្លើយតបនឹងសំនួររបស់បងប្អូន ដូចតទៅ

- តើត្រូវចុះឈ្មោះកូនខ្ញុំនៅសាលារៀន នៅអនុវិទ្យាល័យ ឬនៅវិទ្យាល័យ ?
- កូនខ្ញុំមិនចេះនិយាយភាសាបារាំងទេ ។ តើមានសំណើអ្វីពីសាលារៀន ពីអនុវិទ្យាល័យ និងពីវិទ្យាល័យ ?
- តើប្រព័ន្ធសិក្សាធិការនៅប្រទេសបារាំងមានរៀបចំដូចម្តេចខ្លះ ?
- តើមានបុគ្គលិកណាខ្លះដែលសំខាន់នៅសាលារៀន នៅអនុវិទ្យាល័យ និងនៅវិទ្យាល័យ ?
- តើសមាគមណាដែលនៅក្បែរផ្ទះខ្ញុំ អាចជួយបង្រៀនកូនខ្ញុំបន្ថែម ក្រៅពីម៉ោងរៀននៅសាលា ?

## *ការទទួលនៅក្នុងសាលាបឋមសិក្សា នៅក្នុងអនុវិទ្យាល័យ និងនៅក្នុងវិទ្យាល័យ :*

សូមកុំញញើតញញើមនឹងសុំការណាត់ជួបជាមួយនឹង **គ្រូបង្រៀនទាំងឡាយ** ព្រមទាំងជាមួយ **ចាងហ្វាងសាលា** ជាមួយ **នាយកគ្រឹះស្ថានសិក្សា** (នៃអនុវិទ្យាល័យ ឬវិទ្យាល័យ) ជាមួយ **គិលានុបដ្ឋាយិកា** និង **វេជ្ជបណ្ឌិតខាងការសិក្សា** ជាមួយ **អ្នកជំនួយខាងសង្គម** ជាមួយ **ក្រុមប្រឹក្សាខាងតម្រែតម្រង់** ។

## ◆ តើសមាគមណាដែលនៅក្បែរផ្ទះខ្ញុំ អាចជួយបង្រៀនកូនខ្ញុំបន្ថែម ក្រៅពីម៉ោងរៀននៅសាលា?

កាន់តែច្រើនឡើងៗ **សមាគម** ដែលតាំងនៅក្នុងសង្កាត់ ធ្វើការសម្របសម្រួលជាមួយ **សាលារៀន** ជាមួយ **អនុវិទ្យាល័យ** និងជាមួយ **ម.ប.ស.អ.ទ.ធ** ។ តាមអធ្យោបាយរបស់ខ្លួន សមាគមទាំងនោះអាចស្នើដល់ក្មេងនូវ « **ការជួយអមដំណើរក្នុងការសិក្សា**» ក្រោយពេលចេញពីសាលា ឬសកម្មភាពផ្សេងៗដែលជាគុណប្រយោជន៍ដល់ក្មេង ដូចជាការហាត់រៀនភាសាបារាំង និងការចូលរួមជាមួយអ្នកដទៃ ។

សូមទាក់ទងជាមួយគ្រូបង្រៀន ជាមួយចាងហ្វាងសាលា ឬជាមួយនាយកអនុវិទ្យាល័យ : ពួកគេនឹងផ្តល់ព័ត៌មានពីដំណើរការដែលត្រូវធ្វើជាបន្តបន្ទាប់ ដើម្បីចុះឈ្មោះកូនបងប្អូន ក្នុងរចនាសម្ពន្ធខាងលើ ។

---

## ដំណឹងបន្ថែមផ្សេងៗស្តីពីការសិក្សា

សមាគមរបស់បងប្អូននៅក្នុងសង្កាត់ ឬគ្រូបង្រៀនទាំងឡាយ អាចធ្វើឲ្យបងប្អូនមានទំនាក់ទំនងជាមួយអធិការដ្ឋាននៃបណ្ឌិតសភា ឬជាមួយ ម.ប.ស.អ.ទ.ធ ជាមួយក្រសួងសិក្សាធិការជាតិទទួលបន្ទុកជួយសម្រួលការរៀនសូត្រដល់សិស្សថ្មីដែលទើបមកដល់ ។

**អធិការដ្ឋាននៃបណ្ឌិតសភានៅ ភូមិភាគ អារដែន :**
**០៣ ២៤ ៥៩ ៧១ ៥០**
**អធិការដ្ឋាននៃបណ្ឌិតសភានៅ ភូមិភាគ ម៉ាន :**
**០៣ ២៦ ៦៨ ៦០ ០០**
**អធិការដ្ឋាននៃបណ្ឌិតសភានៅ ភូមិភាគ អូប :**
**០៣ ២៥ ៧៦ ២២ ២២**
**អធិការដ្ឋាននៃបណ្ឌិតសភានៅ ភូមិភាគ ម៉ានផ្នែកខាងលើ :**
**០៣ ២៥ ៣០ ៥១ ៥១**

⇦ ⇨

**Inspection Académique des Ardennes :**
**03 24 59 71 50**
**Inspection Académique de la Marne :**
**03 26 68 60 00**
**Inspection Académique de l'Aube :**
**03 25 76 22 22**
**Inspection Académique de la Haute-Marne :**
**03 25 30 51 51**

**C.A.S.N.A.V**
Centre Académique pour la Scolarisation des Nouveaux-Arrivants et des enfants du Voyage

**Ardennes et Marne : 03 26 61 20 39**
**Aube et Haute-Marne : 06 80 40 28 16**
**Site : http://www.ac-reims.fr/casnav/**

⇦ ⇨

**ម.ប.ស.អ.ទ.ធ**
មជ្ឈមណ្ឌលនៃបណ្ឌិតសភា សំរាប់ការសិក្សានៃអស់អ្នកដែលទើបមកដល់ និងកូនអ្នកធ្វើដំណើរ

**ភូមិភាគ អារដែន និង ភូមិភាគ ម៉ាន : ០៣ ២៦ ៦១ ២០ ៣៩**
**ភូមិភាគ អូប និង ភូមិភាគ ម៉ានផ្នែកខាងលើ : ០៦ ៨០ ៤០ ២៨ ១៦**
ស៊ីត : **http://www.ac-reims.fr/casnav/**

## ◆ <u>តើត្រូវចុះឈ្មោះកូនខ្ញុំនៅសាលារៀន នៅអនុវិទ្យាល័យ ឬនៅវិទ្យាល័យ</u>?

<table>
<tr><th></th><th>សាលាមតេយ្យ</th><th>សាលាបឋមសិក្សា</th><th>អនុវិទ្យាល័យ និង វិទ្យាល័យ</th></tr>
<tr><td>លក្ខខ័ណ្ឌ<br>នៃការចុះឈ្មោះ</td><td>សាលារៀនទទួលក្មេងចាប់ពីអាយុ ៣ឆ្នាំ យ៉ាងពេញលេញនៅថ្ងៃទី ៣១ធ្នូ នៃឆ្នាំដែលចូលរៀន (ចាប់ពីអាយុ ២ឆ្នាំ នៅតំបន់អប់រំដែលមានអាទិភាព នៅតំបន់ពិសេស) ។</td><td>ដើម្បីចូលរៀន ថ្នាក់បរិវត្តន៍ដ្ឋាន (C.P) កូនបងប្អូនត្រូវមាន អាយុ ៦ឆ្នាំ មុនថ្ងៃទី ៣១ ធ្នូ នៃឆ្នាំដែលចូលរៀន ដោយកំរិតតាមកន្លែងដែលមាន ។</td><td>ប្រសិនបើកូនបងប្អូនគ្រប់អាយុចូលរៀនមធ្យមសិក្សា ជាដំបូងត្រូវទៅជួបនឹង អ្នកប្រឹក្សាម្នាក់ខាងតម្រែតម្រង់ គេនឹងធ្វើតេសផ្សេងៗ ដើម្បីប្រមាណកំរិតសិក្សារបស់វា និងសម្បទារបស់វា ។</td></tr>
<tr><td>នីតិវិធី</td><td colspan="2">ដើម្បីចុះឈ្មោះកូនបងប្អូននៅសាលា<br>ចាំបាច់ត្រូវទៅទាក់ទងនឹង <u>សាលាសង្កាត់</u><br>ដែលបងប្អូនរស់នៅ ។<br>សាលាសង្កាត់នឹងធ្វើសំបុត្របញ្ជាក់ពីការចុះឈ្មោះមួយសន្លឹក<br>ដែលត្រូវយកទៅបង្ហាញនាយកសាលា<br>ជាមួយនឹងឯកសារ ដូចខាងក្រោមនេះ ៖</td><td>ជាដំបូង សូមទៅទាក់ទងនឹង<br><u>អធិការដ្ឋាននៃបណ្ឌិតសភា</u><br>គេនឹងកំណត់ជំនួបមួយជាមួយអ្នកប្រឹក្សាម្នាក់ខាងតម្រែតម្រង់ នៅឯ មជ្ឈមណ្ឌលផ្តល់ព័ត៌មាន និងតម្រែតម្រង់ (ម.ព.ត) ដែលនៅជិតជាងគេ ។<br>ទៅតាមកន្លែងដែលសល់ទំនេរ និងទៅតាមទីកន្លែងរស់នៅរបស់បងប្អូន អធិការនៃបណ្ឌិតសភា នឹងបញ្ជូនកូនបងប្អូនឲ្យទៅរៀននៅគ្រឹះស្ថានមួយក្នុងថ្នាក់ដែលស្របទៅតាមកំរិតរបស់វា ។ ដូច្នេះត្រូវទៅជួបលោកនាយកអនុវិទ្យាល័យ ឬវិទ្យាល័យ អោយបានឆាប់បំផុត ។</td></tr>
<tr><td>ឯកសារនានា<br>ដែលត្រូវស្នើរក</td><td colspan="3">➢ សំបុត្រកំណើតក្មេង មួយសន្លឹក និងសំបុត្រកំណើតអ្នកទទួលខុសត្រូវ មួយសន្លឹក ឬសៀវភៅគ្រួសារ<br>➢ ឯកសារសិក្សាផ្សេងៗពីមុន ប្រសិនបើមាន<br>➢ លិខិតបញ្ជាក់ទីកន្លែងរស់នៅ មួយសន្លឹក<br>លិខិតពេទ្យមួយសន្លឹក បញ្ជាក់ថា ក្មេងបានចាក់ថ្នាំការពារដែលខានមិនបាន តាមអាយុរបស់វា និងបញ្ជាក់ថា ក្មេងមានសម្បទាតាមវេជ្ជវិទ្យា ក្នុងការរស់នៅរួមជាមួយអ្នកឯទៀត ។</td></tr>
</table>

## ◆ <u>តើប្រព័ន្ធសិក្សាធិការនៅប្រទេសបារាំងមានរៀបចំដូចម្តេចខ្លះ</u>?

***<u>ជាដំបូង សូមជ្រាបដូចតទៅនេះ :</u>***

**នៅប្រទេសបារាំង ការសិក្សាជា ការខានមិនបាន ពី៦ ដល់ ១៦ ឆ្នាំ**

ក៏ប៉ុន្តែ ក្មេងអាចទៅសាលារៀនតាំងពីអាយុ ៣ឆ្នាំ
ហើយយុវជនដែលមានអាយុលើសពី ១៦ឆ្នាំ ក៏អាចបន្តការសិក្សាបានដែរ ។

**សាលារៀនមានភាពជា សាធារណៈ គ្រហស្ថ និង អត់បង់ថ្លៃ**

មានសាលារៀន ឬអនុវិទ្យាល័យឯកជនជាច្រើនដែរ តែត្រូវបង់ថ្លៃឈ្នួលសិក្សា ។

គ្រឹះស្ថានសិក្សាទាំងឡាយទទួលទាំងស្រី ទាំងប្រុសឲ្យរៀនថ្នាក់ជាមួយគ្នា ។

## *ការពិពណ៌នាអំពីដំណើរនៃការសិក្សា*

*សូមអានតារាង ដោយចាប់ផ្តើមពីខាងក្រោម*

<table>
<tr><td>ឧត្តមសិក្សា<br></td><td>សាកលវិទ្យាល័យ<br>ឬ<br>សាលាជាន់ខ្ពស់</td><td colspan="4">បន្ទាប់ពីជាប់មធ្យមសិក្សាប័ត្រ ការសិក្សាទៅថ្នាក់លើ អាចមានរយៈពេល ពី ២ ទៅ ៨ឆ្នាំ ទៅតាមសញ្ញាប័ត្រដែលបានប៉ងប្រាថ្នា ។<br>ដើម្បីមានការទទួលយល់ព្រមនូវការសិក្សាទាំងនេះ ចាំបាច់ត្រូវផ្តល់សញ្ញាប័ត្រ និងវិញ្ញាបនប័ត្រសិក្សាដែលបានពីប្រទេសរបស់បងប្អូន ។</td></tr>
<tr><td rowspan="7">មធ្យមសិក្សា<br></td><td rowspan="3">វិទ្យាល័យ<br>ទូទៅ,<br>បច្ចេកទេស<br>ឬ<br>វិជ្ជាជីវៈ</td><td>ថ្នាក់ទីបញ្ចប់ សំរាប់ មធ្យមសិក្សាប័ត្រទូទៅ ឬ មធ្យមសិក្សាប័ត្របច្ចេកទេស</td><td>មធ្យមសិក្សាប័ត្រ ខាងវិជ្ជាជីវៈ<br>(រយៈពេល ២ឆ្នាំ)</td><td colspan="2" rowspan="3">ទៅតាមដំណើរនៃសិក្សាដែលបានជ្រើសរើស ការសិក្សានៅវិទ្យាល័យអាចមានរយៈពេល ២ឆ្នាំ, ៣ឆ្នាំ ឬ ៤ឆ្នាំ</td></tr>
<tr><td>ថ្នាក់ទី ១</td><td>ប្រកាសនីយប័ត្រសិក្សាវិជ្ជាជីវៈ<br>ឬវិញ្ញាបនប័ត្រសិក្សាវិជ្ជាជីវៈ</td></tr>
<tr><td>ថ្នាក់ទី ២</td><td>ថ្នាក់ទី ២ ខាងវិជ្ជាជីវៈ</td></tr>
<tr><td rowspan="4">អនុវិទ្យាល័យ</td><td colspan="2">ថ្នាក់ទី ៣</td><td>១៤-១៥ ឆ្នាំ</td><td rowspan="4">ក្នុងពេល ៤ឆ្នាំនេះ មានបញ្ចប់ដោយការប្រឡងមួយ គឺ ប្រកាសនីយ-ប័ត្រនៃអនុវិទ្យាល័យ</td></tr>
<tr><td colspan="2">ថ្នាក់ទី ៤</td><td>១៣-១៤ ឆ្នាំ</td></tr>
<tr><td colspan="2">ថ្នាក់ទី ៥</td><td>១២-១៣ ឆ្នាំ</td></tr>
<tr><td colspan="2">ថ្នាក់ទី ៦</td><td>១១-១២ ឆ្នាំ</td></tr>
<tr><td rowspan="8">បឋមសិក្សា<br></td><td rowspan="5">សាលាបឋមសិក្សា</td><td>ថ្នាក់មជ្ឈិមដ្ឋានទី ២</td><td rowspan="3">ភូមិសិក្សាទី ៣</td><td>១០-១១ ឆ្នាំ</td><td rowspan="5">គ្មានការប្រឡងទេ ពេលចេញពីសាលាបឋមសិក្សា</td></tr>
<tr><td>ថ្នាក់មជ្ឈិមដ្ឋានទី ១</td><td>៩-១០ ឆ្នាំ</td></tr>
<tr><td>ថ្នាក់បឋមសិក្សាទី ២</td><td>៨-៩ ឆ្នាំ</td></tr>
<tr><td>ថ្នាក់បឋមសិក្សាទី ១</td><td rowspan="3">ភូមិសិក្សាទី ២</td><td>៧-៨ ឆ្នាំ</td></tr>
<tr><td>ថ្នាក់បរិវច្ចនដ្ឋាន</td><td>៦-៧ ឆ្នាំ</td></tr>
<tr><td rowspan="3">សាលាមត្តេយ្យ</td><td>ផ្នែកធំ</td><td>៥-៦ ឆ្នាំ</td><td rowspan="3"></td></tr>
<tr><td>ផ្នែកមធ្យម</td><td rowspan="2">ភូមិសិក្សាទី ១</td><td>៤-៥ ឆ្នាំ</td></tr>
<tr><td>ផ្នែកតូច</td><td>៣-៤ ឆ្នាំ<br>២-៣ ឆ្នាំ</td></tr>
</table>

## ◆ កូនខ្ញុំមិនចេះនិយាយភាសាបារាំងទេ។<br>តើមានសំណើអ្វីពីសាលារៀន ពីអនុវិទ្យាល័យ និងពីវិទ្យាល័យ ?

សិស្សទាំងឡាយណាដែលមិនទាន់ចេះនិយាយបារាំង ឬមិនសូវចេះចំណាប់ភាសាបារាំង ទាំងការសរសេរក្តី ទាំងការនិយាយសាសងក្តី ត្រូវបានទទួលបន្ទុលជាពិសេស នៅក្នុងចំណោមគ្រឹះស្ថានសិក្សាមួយចំនួន ។

ទាំងអស់គ្នាសិក្សា **ក្នុងថ្នាក់ធម្មតា** ស្របទៅតាមអាយុរបស់វា និងទៅតាមកំរិតរបស់វា សិស្សទាំងឡាយណាមិនទាន់ចេះចំណាប់ភាសាបារាំង នឹងមានការប្រមូលអោយទៅរៀន **វិជ្ជាពិសេសដោយឡែក ចំនួន ៤-៥ ម៉ោងក្នុងមួយអាទិត្យ** ដែលមានឈ្មោះថា :

- **CLIN** *(ថ្នាក់ដើមដំបូង)* ឬ **CRI** *(វិជ្ជាសំរាប់តាមគេឲ្យទាន់)* ចំពោះសាលាបឋមសិក្សា
- **CLA** *(ថ្នាក់ទទួល)* ឬ **Dispositif FLE** *(បារាំងភាសារបស់បរទេស)* ចំពោះអនុវិទ្យាល័យ និងចំពោះវិទ្យាល័យ ។

ម៉ោងពិសេសទាំងនេះ មានគោលបំណងផ្ដល់ឲ្យក្មេងៗនូវអធ្យោបាយដើម្បីឲ្យបានលទ្ធផលល្អនៅសាលា និង ដឹងខ្លួនថាស្រួលនៅសាលាយ៉ាងឆាប់បំផុត ។ ជាពិសេសនៅកន្លែងនេះ គេបង្រៀនបារាំង ព្រមទាំងគេផ្ចិតផ្ចង់បង្រៀនពីចំណេះវិជ្ជាចាំបាច់ខ្លះៗ ដើម្បីបានលទ្ធផលល្អក្នុងគ្រប់វិជ្ជាសិក្សាឯទៀតៗដែរ ។ ការចាត់ចែងដោយឡែក និងសកម្មភាពនានា តម្រូវតាមក្មេងៗ បានស្នើឡើងដើម្បីជួយឲ្យសិស្សទើបមកដល់ថ្មី ងាយក្នុងការចូលរួមជាមួយអ្នកដទៃទៀត ។

ប្រសិនបើបងប្អូនរស់នៅក្នុងឃុំតាមជនបទ ការជួយគាំទ្រកូនបងប្អូន គឺរៀបចំឡើងដោយគ្រូបង្រៀននៃគ្រឹះស្ថានសិក្សា ដោយមានបង្អែកពី ម.ប.ស.អ.ទ.ធ ផង ។

## ◆ តើសមាគមណាដែលនៅក្បែរផ្ទះខ្ញុំ អាចជួយបង្រៀនកូនខ្ញុំបន្ថែម ក្រៅពីម៉ោងរៀននៅសាលា ?

### អ្នកជំនួយខាងសង្គម

**<u>នៅសាលាបឋមសិក្សា</u>**

គ្មានអ្នកជំនួយខាងសង្គមនៃក្រសួងអប់រំជាតិទេ នៅសាលាបឋមសិក្សា ។ ក្នុងករណីមានបញ្ហា ចាំបាច់សូមទាក់ទងនឹងអង្គការខាងសង្គមក្នុងសង្កាត់ ដែលបងប្អូនរស់នៅ ។

**<u>នៅអនុវិទ្យាល័យ ឬនៅវិទ្យាល័យ</u>**

អ្នកជំនួយខាងសង្គមរង់ចាំស្ដាប់សិស្ស និងគ្រួសារសិស្សជានិច្ច (ពាក្យសុំសួរដំណឹង, សេចក្ដីត្រូវការនិយាយ, ផលវិបាកខាងប្រាក់ចំណូល, ...) សូមកុំញញើតញញើមនឹងសុំណាត់ជួបជាមួយអ្នកជំនួយនេះ ។ គាត់ធ្វើការរួមជាមួយនឹងបុគ្គលិកទាំងអស់នៃគ្រឹះស្ថានសិក្សា ។ គាត់បានទទួលការហាមប្រាមពីការស្ងាត់ស្ងៀមខាងវិជ្ជាជីវៈ ។

### អ្នកប្រឹក្សាខាងតម្រែតម្រង់ចិត្តវិទូ (ប.ត.ច)

នៅអនុវិទ្យាល័យ និងនៅវិទ្យាល័យ អ្នកប្រឹក្សាធ្វើការជាអចិន្ត្រៃយ៍ ។ គាត់ផ្ដល់ព័ត៌មានស្ដីពីលទ្ធភាពផ្សេងៗនៃការសិក្សា និងពីរបរចិញ្ចឹមជីវិត ។ ទៅជួប (ប.ត.ច) ផ្ដល់ឱកាសឲ្យកូនបងប្អូនធ្វើតុល្យការស្ដីពីសមត្ថភាពរបស់វា និងពីការដឹងហេតុផលរបស់វា ដើម្បីគ្រោងទុកជាមុននូវការតម្រែតម្រង់គោលដៅរបស់វា ។

### នាយកក្រុមប្រឹក្សាខាងការអប់រំ (ន.ប.អ)

ដោយមានជំនួយពីអនុរក្សទាំងឡាយផងនោះ នាយកក្រុមប្រឹក្សាខាងការអប់រំ ជាអ្នកទទួលខុសត្រូវលើការចាត់ចែង និងលើដំណើរការនៃការរស់នៅជារៀងរាល់ថ្ងៃ ក្នុងអនុវិទ្យាល័យ ឬក្នុងវិទ្យាល័យ ។ គាត់គិតគូរពីការមកសាលារៀនយឺតយ៉ាវរបស់សិស្ស និងអវត្តមានរបស់សិស្ស ។ ជាពិសេស គាត់ជាគូសន្ទនាខាងអប់រំមួយយ៉ាងសំខាន់សំរាប់បងប្អូន និងសំរាប់កូនបងប្អូន ។

### គិលានុបដ្ឋាយិកា នៃក្រសួងអប់រំជាតិ

**<u>នៅសាលាបឋមសិក្សា</u>**

តាមពាក្យសុំរបស់បងប្អូន គិលានុបដ្ឋាយិកាម្នាក់នៃក្រសួងអប់រំជាតិ ឬវេជ្ជបណ្ឌិតម្នាក់ខាងការសិក្សា អាចកោះហៅ តាមរយៈគ្រូបង្រៀនកូនបងប្អូន ដើម្បីឲ្យបងប្អូនមកជួបគេនៅសាលារៀន ។ យ៉ាងឆាប់បំផុត គិលានុបដ្ឋាយិកា ឬវេជ្ជបណ្ឌិតខាងការសិក្សា នឹងជួបកូនបងប្អូន ដើម្បីធ្វើតុល្យការមួយខាងសុខភាព ។

**<u>នៅអនុវិទ្យាល័យ ឬនៅវិទ្យាល័យ</u>**

នៅអនុវិទ្យាល័យ គិលានុបដ្ឋាយិកាម្នាក់មកប្រចាំការតែថ្ងៃខ្លះប៉ុណ្ណោះនៃសប្ដាហ៍ ។ ចំណែកនៅវិទ្យាល័យវិញ គឺគាត់មកប្រចាំការរៀងរាល់ថ្ងៃ ។ គាត់ទទួលសិស្សដើម្បីធានាតែការព្យាបាលជាចាំបាច់បំផុត ។ សិស្សអាចរៀបរាប់ប្រាប់គាត់ពីកង្វល់ផ្សេងៗរបស់ខ្លួន ឬពីទិដ្ឋភាពទាំងអស់ស្ដីពីសុខភាព មាន (វិធានការបង្ការ ឬដំបូន្មានខាងសុខភាពខាងការចិញ្ចឹមជីវិត ខាងអនាម័យ ...) នៅក្នុងអំឡុងឆ្នាំសិក្សា សិស្សនឹងបានទទួលតុល្យការពេទ្យមួយ ។ គិលានុបដ្ឋាយិកាអាចជួបជាមួយនឹងគ្រួសារបាន ។ គាត់បានទទួលការហាមប្រាមពីការស្ងាត់ស្ងៀមខាងវិជ្ជាជីវៈ ។

### នាយកសាស្ត្រាចារ្យនៅអនុវិទ្យាល័យ និងនៅវិទ្យាល័យ

គាត់ជាគូសន្ទនាដែលមានសិទ្ធិពិសេសសំរាប់សិស្ស ជាអ្នកបង្រួបបង្រួមក្នុងករណីមានជម្លោះ ជាអ្នកសម្របសម្រួលនៃក្រុមសាស្ត្រាចារ្យ ។ នាយកសាស្ត្រាចារ្យ ជាអ្នកដែលគ្រួសារតែងទៅជួបជាញឹកញាប់ ។ សូមកុំញញើតញញើមនឹងសុំការណាត់ជួបជាមួយគាត់ ដើម្បីរៀបរាប់ពីបញ្ហាក្នុងថ្នាក់ ពីភាពចម្រុងចម្រើន ឬការពិបាករបស់កូនបងប្អូន ។